# ការទិតៀនក្នុងន័យស្ថាបនា

ការទិតៀនក្នុងន័យស្ថាបនា គឺជាមធ្យោបាយមួយ ដើម្បីផ្តល់គំនិតរបស់អ្នកលើសកម្មភាពរបស់អ្នកណាម្នាក់ ដោយគ្មានការបន្ទោស ឬការសន្និដ្ឋាន ប៉ុន្តែជាមួយនឹងការកែលំអ និងអភិវឌ្ឍន៍សមត្ថកិច្ចបុគ្គលដែលត្រូវគេទិតៀន ។

## ចំនុចសំខាន់នៃការទិតៀនស្ថាបនា:

១. ការទិតៀនស្ថាបនា គួរជាការទិតៀនដែលពោរពេញដោយការគោរពដល់អ្នកដទៃ ។

២. វាគួរតែមានការយល់ចិត្តគ្នាទៅវិញទៅមក រវាងអ្នកផ្តល់ការទិតៀន និងអ្នកត្រូវគេទិតៀន ។

៣. ការផ្តល់ការទិតៀន ត្រូវប្រកបដោយសេចក្តីស្មោះត្រង់ ហើយចេះផ្តល់គំនិតកែលំអដែលប្រកបដោយការលើកទឹកចិត្ត ។

៤. ការផ្តល់ការទិតៀន គួរតែមានការស្នើសុំ និងយល់ព្រមពីអ្នកដែលយើងត្រូវផ្តល់ ។

៥. ការទិតៀនមិនមែនជាការស្តីបន្ទោសដល់អ្នកដទៃនោះទេ ។ ពាក្យសំដីទិតៀនសមរម្យ និងសមស្រប គួរតែត្រូវបានយកមកប្រើ ។

៦. នៅពេលដែលទិតៀននរណាម្នាក់ ប្រើគំនិតទិតៀនចេញពីខ្លួនអ្នក មិនត្រូវទិតៀនជំនួសអ្នកដទៃទេ ។

៧. ការទិតៀនត្រូវធ្វើឡើងដោយបង្ហាញអំពីអារម្មណ៍ ការចាប់អារម្មណ៍ ឬតំរូវការរបស់ខ្លួនឯងមុន ។ ដោយហេតុនោះអ្នកអាចជៀសវាងការធ្វើសន្និដ្ឋាន ឬបន្ទោសអ្នកដទៃ ។

| | |
|---|---|
| កុំនិយាយថា: | "អ្នកធ្វើនេះ អ្នកធ្វើនោះ..." , "អ្នកមិនបានឱ្យឧទាហរណ៍គ្រប់គ្រាន់ទេ" |
| ប៉ុន្តែនិយាយថា: | "ខ្ញុំដូចជាច្រឡំ ។" , "ខ្ញុំមិនអាចយល់បានទេ ។" , "ខ្ញុំចង់បានឧទាហរណ៍បន្ថែមទៀត ។", "វាពិបាកណាស់ ខ្ញុំតាមមិនទាន់ទេ ។ ខ្ញុំមិនយល់ពាក្យពិបាកៗទេ ។" |

៨. សូមចាប់ផ្តើមទិតៀនតែចំនុចណាដែលសំខាន់ៗ និងអ្វីដែលងាយស្រួលកែលំអ( មួយជំហានម្តងៗ) ។ ពីព្រោះ អ្នកទទួលការទិតៀនអាចរៀនឱ្យបានច្បាស់លាស់ពីអ្វីដែលអាចកែលំអបានពិតប្រាកដ ។ ត្រូវចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវបញ្ហាដែលត្រូវទិតៀន កុំធ្វើការទិតៀនជាទូទៅ ។

| | |
|---|---|
| កុំនិយាយថា: | "សុន្ទរកថាទាំងមូលរបស់អ្នកមានលក្ខណៈមិនច្បាស់លាស់" |
| ប៉ុន្តែនិយាយថា: | "ខ្ញុំចង់បានការពន្យល់ណែនាំបន្ថែមទៀតលើចំនុចខាងដើម ។" ឬ "ខ្ញុំចង់បានគំនូសបង្ហាញបន្ថែមទៀតនៅលើក្តារខៀន ។" |

៩. ការនិយាយទិតៀនត្រូវលើកពីចំនុចវិជ្ជមានជាមុនជានិច្ច បន្ទាប់មកទើបធ្វើការទិតៀន ។

| | |
|---|---|
| កុំនិយាយថា: | "ខ្ញុំមិនចូលចិត្តចំនុចនេះ ចំនុចនោះ ប៉ុន្តែជាសរុបមក វាប្រសើរហើយ ។" |
| ប៉ុន្តែនិយាយថា: | "ខ្ញុំពេញចិត្តនឹងរូបភាពដែលអ្នកលើកមកនោះខ្លាំងណាស់ វាជួយខ្ញុំឱ្យកាន់តែយល់ច្បាស់ ប៉ុន្តែ វាមានលក្ខណៈស្មុគស្មាញបន្តិច ។" |